# បណ្ដាំ អ្នកមានគុណ

| | | | | |
|---|---|---|---|---|
| ១. | ឱកូនប្រុសស្រី | ចូរចាំសំដី | ពុកម៉ែប្រដៅ | ថាបើឆោតល្ងង់ |
| | កុំលង់អោយខ្លៅ | កុំធ្លាក់អោយជ្រៅ | ដល់ផ្លូវលែងកែ ។ | |
| ២. | បើល្ងង់អោយឆ្លាត | ត្រូវប្រឹងសង្វាត់ | មើលក្រុងមើលស្រែ | មើលកីតំបាញ |
| | កេរ្តិ៍ពីខ្មោចម៉ែ | មើលសំពត់ព្រែ | កេរ្តិ៍ពីជីដូន ។ | |
| ៣. | រនាស់ន័ង្គាល់ | ដែលបានបន្សល់ | ពីឪពុកកូន | សុទ្ធជាឈើល្អ |
| | កំរណាស្ងួន | ត្រូវខំថែរធួន | កុំលក់កុំដូរ ។ | |
| ៣. | បើឆោតអោយចេះ | គិតយកតំរេះ | មកគិតមុនគួរ | យកមេរៀនចាស់ |
| | ទុកជាគំរូ | មិនត្រូវរអ៊ូរ | ថាចាស់សាំញុាំ ។ | |
| ៤. | ព្រោះចាស់ជាក្បួន | បង្រៀនអោយស្ងួន | ធ្វើអ្នកដឹកនាំ | រៀនធ្វើពីតូច |
| | ទម្រាំដល់ធំ | កុំស្រវ៉ាភ្នំ | មុនមានដំបូក ។ | |
| ៥. | រៀនតាមកណ្ដៀវ | ចេះសាមគ្គីគ្នា | កសាងជំរក | ពីដីរាបស្មើរ |
| | ក្លាយជាដំបូក | មិនត្រូវចូលមក | បានតែសំដី ។ | |
| ៦. | ចេះប្រើសាច់ដុំ | ទោះតូចឬធំ | អោយស្នំសរសៃ | ចេះមានមាត់ករ |
| | អោយសមសំដី | ចេះប្រើជើងដៃ | អោយមានប្រយោជន៍ ។ | |
| ៧. | ដីភូមិក្រោយផ្ទះ | ត្រូវចាំងជំរះ | ស្មៅដែលនាំហោច | ព្រោះបើភូមិស្ដុក |
| | កូនចៅខ្លាចខ្មោច | យប់ថ្ងៃអាសោច | នាំផលមិនល្អ ។ | |
| ៨. | ឱវ៉ាទចាស់ៗ | កូនចាំអោយច្បាស់ | ណាស្ងួនបវរ | ពុកម៉ែស្រលាញ់ |
| | ទើបទូលមានល្អ | ខ្លាចកូនភ្លេចល្អ | ប្រព្រឹត្តិអាក្រក់ ។ | |

៩. សត្រូវជាញាត្តិ គេពិតជាឆ្នៀត លួចបំពក់ភ្ញក់ បក់ផ្សែងបង្កុយ
លើយើងអោយឈ្លក់ ដើម្បីពង្វក់ អោយកូនវង្វេង ។
១០. តែទោះយ៉ាងណា កូនត្រូវហានក្លា ចេះស្គាល់ខ្លួនឯង ឈរជើងអោយនឹង
កុំពឹងអ្នកផ្សេង ត្រូវហ៊ានទប់ជ្រែង បើគេផ្តន្ទា ។
១១. ពូជជាសត្រូវ មិនដែលទុកផ្លូវ សំរាប់ស្ងួនភ្ងា មានតែឈ្នានីស
ចងកម្មចងពៀ អោយកូនវេទនា ទើបគេសប្បាយ ។
១៣. តែបើកូនភ្លេច នូវរាល់ពាក្យពេចន៍ ដែលឪពុកម្តាយ ខំដាស់រំលឹក
កូននឹងអន្តរាយ សូម្បីភូមិម្តាយ ក៏គេយកដែរ ។
១៤. សត្រូវមានក្បួន មិនថា សៀម យួន គឺគេពូកែ ប្រើល្បិចទាក់ទាញ
អោយកូនលង់ស្នេហ៍ ភ្លេចពាក្យ ឪ ម៉ែ បែជឿពាក្យគេ ។
១៥. ចូរកូនត្រូវចាំ បើជាតិប្រេះស្រាំ ដី ភ្នំ ទន្លេ ដែលដូនតាយើង
ទុកអោយជាកេរ្តិ៍ នឹងត្រូវពួកគេ ប្លន់យកអស់ហើយ ។
១៦. កុំលង់ដំណេក កុំដេកអោយភ្លឹក ព្រឹកហើយកូនអើយ កូនពៅពន្លក
ពុក ម៉ែ លាហើយ សូមកុំព្រងើយ គិតឆ្លើយអោយច្បាស ។/

សហរដ្ឋអាមេរិក ថ្ងៃទី ១០ កញ្ញា ២០០៦

**សួន សេរីរដ្ឋា (ដែនដីសេរីភាព)**